មជ្ឈមណ្ឌលឯកសារកម្ពុជា

របាយការណ៍សង្ខេប
សម្រាប់ការងារកោសល្យវិច័យឆ្អឹងនៅខែសីហា ឆ្នាំ២០០៣

# កំពង់ចាម

*វិទ្យាល័យស្រីសន្ធរ (មន្ទីរសន្តិសុខ និងទីតាំងសម្លាប់)*

វិទ្យាល័យស្រីសន្ធរ គឺជាមន្ទីរសន្តិសុខរបស់ខ្មែរក្រហមតាំងពីឆ្នាំ១៩៧៣ គឺបន្ទាប់ពីស្រុកស្រីសន្ធរត្រូវធ្លាក់ក្នុងការកាន់កាប់របស់ខ្មែរក្រហម ។ ជនរងគ្រោះដែលជាទាហានឈ្លើយសឹកនៃរបបសាធារណរដ្ឋខ្មែរជាច្រើននាក់បានក្លាយជាអ្នកទោសនៅមន្ទីរសន្តិសុខនេះ ។ ពីឆ្នាំ១៩៧៥រហូតដល់ថ្ងៃរំដោះទី៧ ខែមករា ឆ្នាំ១៩៧៩ មន្ទីរសន្តិសុខនេះត្រូវស្ថិតនៅក្នុងភាពទំនេរ ព្រោះបន្ទាប់ពីថ្ងៃជ័យជំនះទាំងស្រុងរបស់ខ្មែរក្រហមនាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥មក មន្ទីរសន្តិសុខនៅវិទ្យាល័យស្រីសន្ធរ ត្រូវផ្លាស់ប្តូរទៅកាន់កន្លែងផ្សេង ។ ក្នុងអំឡុងពេលកាន់កាប់ (១៩៧៣-៧៥) របស់ខ្មែរក្រហម មានជនរងគ្រោះជាច្រើននាក់បានស្លាប់យ៉ាងវេទនានៅបរិវេណខាងក្រោយមន្ទីរ ។ រហូតមកដល់សព្វថ្ងៃនេះ ពុំមានការបញ្ជាក់ណាមួយពីរឿងជីកគាស់រណ្តៅទាំងនោះរកមាស ឬវត្ថុផ្សេងឡើយ ។

ទៀង អួន អាយុ៤១ឆ្នាំ រស់នៅក្នុងភូមិព្រែកពោធិ៍ក្រោម ឃុំព្រែកពោធិ៍ ដែលបច្ចុប្បន្នជាជាងម៉ាស៊ីន បានសន្និដ្ឋានថាមានចំនួនសាកសពប្រមាណ៥០០នាក់បានស្លាប់នៅក្នុងរណ្តៅជាច្រើននៅប៉ែកខាងក្រោយជាប់នឹងរបងវិទ្យាល័យ ។

*ឡពាង (ទីតាំងសម្លាប់)*

ឡពាងបានក្លាយជាទីតាំងសម្លាប់មនុស្សក្នុងចន្លោះពេលនៃការកាន់កាប់របស់ខ្មែរក្រហមឆ្នាំ ១៩៧៥-១៩៧៩ ។ ការសម្លាប់នៅនឹងទីតាំងនេះត្រូវបានប្រព្រឹត្តឡើងរហូតដល់ឆ្នាំ១៩៧៨ ដែលពេលនោះគឺជាការកាន់កាប់របស់ខ្មែរក្រហមខាងភូមិភាគនិរតី ។

វ៉ាន់ ឌិន អាយុ៥៨ឆ្នាំ រស់នៅភូមិព្រែកពោធិ៍ក្រោម ឃុំព្រែកពោធិ៍ បានជួបប្រទះឃើញមានឆ្អឹងមួយចំនួនជាប់មងរបស់គាត់ នៅពេលដែលគាត់លើកមងរបស់គាត់រកត្រីនោះ ។ វ៉ាន់ឌិន និយាយបន្តថា គាត់បានរាយមងរបស់គាត់នៅតាមដងទន្លេដែលស្ថិតនៅជាប់នឹងមាត់ច្រាំងទន្លេកាលពីដីច្រាំងទន្លេមិនទាន់បាក់ស្រុតមកក្នុងទឹកទន្លេ។ ការបាក់ច្រាំងទន្លេ បានកើតឡើងជារៀងរាល់ឆ្នាំនារដូវទឹកគម្រើង ។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ក៏មានប្រភពអះអាងថានៅមានរណ្តៅជាច្រើនទៀតដែលពុំទាន់បានគាស់ និងកំពុងត្រូវបានដាំដើមចេកពីលើ ។

*ស្រុកកំពង់សៀម*

*ទីតាំងគោកព្រីង (ឃុំវិហារធំ)*

មានសាកសពប្រហែល ២៥០០នាក់ បានកប់នៅនឹងរណ្តៅពី៥០-៧០រណ្តៅនៃទួលគោកព្រីង ។ កាក់ ស្រឿន បាននិយាយថា សាកសពគឺជាប្រជាជនចម្រុះទាំងក្មេង ចាស់ ប្រុស ស្រី ។ ភាពក្រហេងក្រហូងនៃរណ្តៅទាំងអស់ បានក្លាយជាការងាយចាំ និងងាយរាប់នូវចំនួនរណ្តៅ ។ ពុំមានការបញ្ជាក់ពីការគាស់រណ្តៅទាំងនោះឡើយ ។ ចំណែកឯវត្តដែលស្ថិតនៅក្បែរទួលនេះ ក៏ពុំមានដាក់តម្កល់ឆ្អឹងសាកសពដែរ ។

# កំពង់ឆ្នាំង

*ព្រៃខ្មោច (ទីតាំងសម្លាប់)*

ព្រៃខ្មោច ជាព្រៃមួយដែលគ្មានមនុស្សរស់នៅ ហើយស្ថិតនៅឆ្ងាយដាច់ស្រយាលពីភូមិដែលមានប្រជាជនរស់នៅ ។ ទីតាំងនេះស្ថិតនៅក្នុងភូមិអូរលាច ឃុំបន្ទាយព្រាល ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ។ ការធ្វើដំណើរទៅកាន់ទីតាំងព្រៃខ្មោចមិនមែនងាយស្រួលឡើយ គឺត្រូវឆ្លងកាត់អូរ ព្រៃរបោះ និងផ្លូវពិបាក ។ កាលពីជំនាន់សង្គមរាស្ត្រនិយម និងលន់ ណុល ព្រៃនេះគឺជាព្រៃសម្រាប់កប់ខ្មោចប្រជាជនដែលបានស្លាប់ដោយសារជម្ងឺ ឬខបត្តិហេតុផ្សេងៗ ។ លុះមកដល់សម័យខ្មែរក្រហមព្រៃនេះក៏នៅតែជាកន្លែងដែលកប់ខ្មោចដដែល ។ ប៉ុន្តែបច្ចុប្បន្ននេះ គឺជាព្រៃដែលបោះបង់ចោលគ្មានមនុស្សរស់នៅ ។ ប្រធានភូមិអូរលាចឈ្មោះ អ៊ុក ម៉េត បានប្រាប់ថាមានរណ្តៅសាកសពលើសពី១០រណ្តៅនៅក្នុងទីតាំងព្រៃខ្មោចនេះ ។ ចំណែកឯជនរងគ្រោះវិញ ម៉េត គ្រាន់តែប្រាប់ថាមានចំនួនលើសពី៥០នាក់ ព្រោះពេលដែលគាត់បានទៅឃើញការគាស់នៅឆ្នាំ១៩៨១គឺមានចំនួនប៉ុណ្ណោះមែន ប៉ុន្តែការគាស់នេះនៅមិនទាន់អស់នៅឡើយទេ ។ អ៊ុក គៀន អាយុ៣៩ឆ្នាំ ជាប្រជាពលរដ្ឋរស់នៅក្នុងភូមិអូរលាច ឃុំបន្ទាយព្រាល បានប្រាប់ខ្ញុំថាគាត់បានចូលរួមគាស់រណ្តៅសាកសពមួយក្នុងចំណោមរណ្តៅទាំងជាង១០ដែលបានគាស់ ។ បន្តិចក្រោយមក គៀន បានក្លាយទៅជាអ្នកដឹកជញ្ជូនឆ្អឹងទៅវិញ ។ អដ្ឋិធាតុដែល គៀនបានដឹកជញ្ជូននោះគឺបានដឹកយកទៅតម្កល់ទុកនៅក្នុងបន្ទាយទាហានមួយដែលស្ថិតនៅក្នុងភូមិអូរលាច ។ អដ្ឋិធាតុទាំងនោះគឺមានចំនួន៣រទេះគោ ។ គៀន បានដឹកអដ្ឋិធាតុទាំងនេះដោយផ្ទាល់ ។ គៀន បានប្រាប់ថាគឺជាអដ្ឋិធាតុជនរងគ្រោះដែលបានស្លាប់ក្នុងឆ្នាំ១៩៧៧-៧៨ ។ ចំពោះការបញ្ជូនមនុស្សមកសម្លាប់នៅទីតាំងព្រៃខ្មោចនេះ បានត្រូវរាយការណ៍ប្រាប់ពីឈ្មោះ នុង គួ អាយុ៦៣ឆ្នាំ ជាសមាជិកក្រុមប្រឹក្សាឃុំបន្ទាយព្រាលថា បានយកមកពីមន្ទីរសន្តិសុខមួយកន្លែងដែលស្ថិតនៅចម្ងាយប្រហែល១គីឡូម៉ែត្រប៉ុណ្ណោះពីទីតាំងសម្លាប់ប៉ែកខាងត្បូង ។ មន្ទីរសន្តិសុខនោះគឺជាមន្ទីរសន្តិសុខប្រចាំឃុំបន្ទាយព្រាលដែលមានឈ្មោះថា “គុកអូរលាច” ។ ទីតាំងសម្លាប់នេះ មិនបានបន្សល់ទុកនូវអ្វីដែលជាភស្តុតាងឡើយនៅក្រោយថ្ងៃរំដោះទី៧ ខែមករា ឆ្នាំ១៩៧៩ ក្រៅពីភាពក្រហេងក្រហូងនៃរណ្តៅដែលបាន

បាក់ស្រុតបន្ទាប់ពីសាកសពបានរោទ្រមរល្បះរលួយសាច់អស់ទៅ ។ នៅក្នុងទំហំប្រមាណ២០០ម៉ែត្របួនជ្រុងនៃបរិវេណព្រៃខ្មោច គឺជាទីតាំងសម្លាប់របស់ខ្មែរក្រហម ។ ក្រោយការគាស់រណ្តៅសាកសពនៅឆ្នាំ១៩៨១ ដែលមានចំនួនជាង១០រណ្តៅនេះទៅ នៅមានរណ្តៅជាច្រើនទៀតដែលមិនទាន់បានគាស់ ។

## បាត់ដំបង

នៅម៉ោង ១៧ ខ្ទះ ១៥នាទី ក្រុមស្រាវជ្រាវឯកសារបានទៅដល់មណ្ឌលខគ្រិដ្ឋកម្ម វត្តឯកភ្នំ ភូមិគាគម ឃុំពាមឯក ស្រុកឯកភ្នំ ខេត្តបាត់ដំបង ចម្ងាយ ៧គីឡូម៉ែត្រ ពីសាលាខេត្ត ។

ទីតាំងនេះមាន ១ - គុក និង សន្តិសុខ

២ - កន្លែងសំលាប់ (មុខវត្តឯកភ្នំ)

៣- សារៈមន្ទីរគ្មាន

ទៅដល់ទីនោះយើងបានជួបសាក្សីឈ្មោះ **ឃុត ខួន** អាយុ ៧៣ឆ្នាំ អាចារ្យវត្តឯកភ្នំ គាត់រស់នៅភូមិគាគម ឃុំពាមឯក ស្រុកឯកភ្នំ ខេត្តបាត់ដំបង ។ បច្ចុប្បន្ន ភូមិ ឃុំ ដូចគ្នា គាត់ជាប្រជាជនពីមុនឥឡូវអាចារ្យវត្តឯកភ្នំ ។

គាត់បានដឹងថា វត្តឯកភ្នំនេះជំនាន់ **ប៉ុល ពត** ពួកឃាតករ **ប៉ុល ពត** យកធ្វើសន្តិសុខ គុក និងកន្លែងសម្លាប់មុខវត្ត ៣០០ម៉ែត្រ នៅចំការក្រូច ដី ១ហិកតា បួនជ្រុង រណ្តៅពេញ ធ្វើឲ្យដើមក្រូច ងាប់ដោយសារជាតិប្រៃ ខ្មោចច្រើនពេញចំការ ។

- ប្រភេទជនរងគ្រោះ ស្លាប់នៅទីនេះគឺ : អ្នកជំលៀសចេញពីទីក្រុង ឆ្នាំ១៩៧៥-៧៦ និងអ្នកខុសសីលធម៌ គឺដើរលួចស៊ី ដើម្បីរស់ បំបាត់ការស្រេកឃ្លាន ក្រៅពីនេះយកពីតំបន់៤ មកដាក់ទីនេះរួចសម្លាប់ ។ នៅទីនោះ ពួក **ប៉ុល ពត** យកព្រះវិហារជាគុក សាលាឆាន់ជាគុក ឯកន្លែងពួកវាស្នាក់នៅស្ថិតនៅខាងក្នុងកុដិ និងប្រាសាទ ។

- សន្តិសុខ និងគុក កន្លែងសម្លាប់ ទីនេះបង្កើតឡើងពីឆ្នាំ១៩៧៥-៧៦-៧៧ រហូតឆ្នាំ១៩៧៨ សម្លាប់ ៣ឆ្នាំ ។ គាត់ប៉ាន់ស្មានរណ្តៅប្រហែល២០០រណ្តៅ ក្នុងបរិវេណ និងក្នុងចំការក្រូច ពេញ ។

សាក្សីទី២ ឈ្មោះ **ញឹម វ៉ាន់** អាយុ ៦៩ឆ្នាំ សព្វថ្ងៃរស់នៅភូមិគស់ហាស ឃុំពាមឯក ស្រុក ខេត្ត ដូចសាក្សីទី១ដែរ ។ គាត់ដឹងថា ទីនោះមានក្មេងចាស់ ប្រុស ស្រី ចំរុះ គេដឹកយកមកពីគ្រប់មជ្ឈដ្ឋានដាក់ទីនោះ រួចសម្លាប់ទាំងអស់ គ្មានសល់ឡើយ ។ ព្រៃផ្សេបំផុត សម្លាប់រួច ចងផ្អែកគល់អំពិលដាក់បារីអោយបៀមមាត់ បញ្ឈរគល់អំពិល ។ ពត៌មានផ្សេងៗដូចសាក្សីទី១ដែរ ។ ថ្ងៃទី២.៥.៩៧ ចប់ការងារម៉ោង ១៨:០០ នៅវត្តឯកភ្នំនោះ ។

## ខេត្តកំពត

- កន្លែងពិឃាត ព្រៃតាគុយ ឋិតក្នុងភូមិតំណាក់ក្រសាំង ឃុំប្រភ្នំ ស្រុកអង្គរជ័យ ខេត្តកំពត ។ ចម្ងាយពីគុកប្រហែល ១គីឡូម៉ែត្រ ។

ទីតាំងនេះពីមុនព្រៃឫស្សីព័ទ្ធជុំវិញត្រពាំងកណ្ដាល រណ្ដៅជុំវិញត្រពាំងក្នុងត្រពាំងបរិវេណសម្លាប់ ៥០ម៉ែត្រ ទៅ ៦០ បួនជ្រុង ពោរពេញទៅដោយរណ្ដៅ អ្នកជាប់គុកបានជីករាល់ថ្ងៃ អ្នកជាប់មុនជីកទុកតៗគ្នា ជីករួចពួកឃាតករសម្លាប់ ។

ទីតាំងសំគាល់បច្ចុប្បន្ន មានដើមត្នោតមួយដើម ដើមក្រសាំង ៣ដើម និងទួលសងខាងត្រពាំងកណ្ដាល ជនរងគ្រោះសម្លាប់ទីនេះចាប់វាយពីម៉ោង ៤ល្ងាច រហូតទល់ភ្លឺ កំណត់មួយយប់សម្លាប់ ២៥០ នាក់ ។

<u>ព័ត៌មានបន្ថែម</u> ព័ត៌មានរៀបរាប់ខាងលើនេះបានពិនិត្យផ្ទាល់របស់យើង ក្រុមស្រាវជ្រាវយើងបានដឹងពីសាក្សីឈ្មោះ :

ទី១ លោកតា **ឆេព ប៉ាន** អាយុ ៦៨ឆ្នាំ ជាអាចារ្យវត្ត ពីមុនគាត់បានដឹងដោយសារបងគាត់ជាប់គុក នៅគុក ភូមិឫស្សីជុំនេះ ។

សាក្សីទី២ **ឌុក ថន់** អាយុ ៧២ឆ្នាំ សម័យ **ប៉ុល ពត** នៅភូមិតាម៉ន (ឫស្សីជុំ) ឃុំប្រភ្នំ ស្រុកអង្គរជ័យ ខេត្តកំពត ក្រោយឆ្នាំ១៩៧៩ នៅភូមិឃុំស្រុក ខេត្ត ដូចពីមុន គាត់ជាសាក្សីដ៏សំខាន់ ជាប្រជាជនបានឃើញផ្ទាល់នឹងភ្នែករាល់ៗថ្ងៃ គេបណ្ដើរបងប្អូនជនរងគ្រោះទាំងខ្សែៗ យកមកដាក់គុកហើយសម្លាប់រាល់យប់ រយៈពេលមុនឆ្នាំ១៩៧៥ គឺ ១៩៧៤-១៩៧៥ ទល់ឆ្នាំ១៩៧៨-១៩៧៩ ។

ប្រភេទជនរងគ្រោះសម្លាប់នៅព្រៃតាគុយនេះ គុកដូចជំរាបនេះមាន :

- មុនឆ្នាំ ១៩៧៥ គឺឆ្នាំ១៩៧៣-៧៤ សម្លាប់មួយៗបណ្ដើរៗ អ្នកមូលដ្ឋានបដិវត្តន៍កម្មាភិបាល ឬ មន្ត្រីក្រែត អ្នកមានបងប្អូន ធ្វើការនៅទីក្រុង វាចោទថា គេញខ្មាំងបង្កប់ ។
- សម្លាប់ពីឆ្នាំ១៩៧៥ ពួក ១៧មេសា ឆ្នាំ១៩៧៥ ពួកមន្ត្រីរដ្ឋការស៊ីវិល ទាហ៊ាន ប៉ូលីស ប៉េអ៊ឹម គេញ គយ ។ល។ អ្នកជំលៀសចេញពីទីក្រុង ។
- បន្តពីឆ្នាំ១៩៧៦-៧៧-៧៨ សម្លាប់ខ្លាំងបំផុត គឺឆ្នាំ១៩៧៨ ។
- អ្នកស្លាប់ទីនោះទាំងគ្រួសារៗ ហើយចំរុះ មានខ្មែរ ចិន យួន ចាម និងពួកអ៊ឺរ៉ុប ខ្លះទៀតផងមានខ្មែរកម្ពុជាក្រោមផងដែរ ។

\+ អំពើទារុណកម្ម

តាមការបំភ្លឺរបស់សាក្សី គាត់បានប្រាប់យើងថា ចងព្យួរក យោលរួចវាយ ចងជើងឡើងក្បាលចុះក្រោម (ពេលសួរចម្លើយ) ។ មួយចំនួនទៀតចងកអូសតាមសេះ ។ (អ្នកខ្លះស្លាប់កំពុងអូស)

អំពីរណ្ដៅ ៖ យើងបានពិនិត្យ និងតាមការបំភ្លឺសាក្សី ពេលគាត់ឃើញផ្ទាល់គេគាស់យកមាសឆ្នាំ ១៩៧៩-១៩៨០ រណ្ដៅធំៗ ៥៨នាក់ ក្មេងចាស់ ប្រុស ស្រី រណ្ដៅធំខ្លះទៀត ១៣៥នាក់ មានរណ្ដៅខ្លះ សុទ្ធតែស្រីៗ ស្រាតទាំងអស់ ដូច្នេះគុកដាក់ស្រីៗ ពួកវាសម្លាប់សុទ្ធតែស្រីៗ គឺជាការពិត ។ រណ្ដៅសរុប ១៣៦ គិតរណ្ដៅធំៗ តូចៗមិនទាន់គាស់ នេះព្រៃតាគុយ ជនរងគ្រោះស្លាប់ មានប្រហែល ៣២.០៤៧នាក់ ។

## ខេត្តកណ្ដាល

វត្តខ្នុររកា ស្ថិតនៅក្នុងភូមិខ្នុររកា ឃុំបារ៉ុង ស្រុកល្វាឯម ខេត្តកណ្ដាល ។ មានរណ្ដៅសាកសពច្រើនណាស់ដែលពុំទាន់បានគាស់យកឆ្អឹងមកដាក់តម្កល់ ។ រណ្ដៅទាំងតូចធំ ត្រូវគ្របដណ្ដប់ដោយរុក្ខជាតិនានាក្នុងពេលបច្ចុប្បន្ននេះ ។ នៅរដូវវស្សាទឹកជំនន់អាចលិចអស់មួយចំនួននៃរណ្ដៅ និងខ្លះទៀតមិនទទួលការរាតត្បាតពីទឹកជំនន់ឡើយ ។ ប៉ុន្តែចំពោះការធ្វើដំណើរ គឺចាំបាច់ត្រូវតែឆ្លងទឹក ។ នៅជុំវិញបរិវេណវត្ត គឺជារណ្ដៅតូចនិងរណ្ដៅធំដែលពោរពេញទៅដោយសាកសពយ៉ាងច្រើន ។ យោងតាមរបាយណ៍កាលពីឆ្នាំ១៩៩៩ ថាមានរណ្ដៅចំនួន ១ ដែលផ្ទុកសាកសពបាន១៦នាក់ មិនទាន់ត្រូវបានគាស់កកាយទេ ហើយជាកន្លែងដែលមិនលិចទឹកជំនន់ផង ។ ទីតាំងនេះស្ថិតនៅចម្ងាយ៥០ម៉ែត្រពីផ្ទះប្រជាជនប៉ែកខាងជើងវត្តខ្នុររកា ។ ចំណែកទីតាំងត្រពាំងតាចាប ក៏មានរណ្ដៅច្រើនណាស់ដែរ ហើយមានកប់សាកសពរាក់ៗផង ។ ទីតាំងនេះក៏មិនទាន់មាននរណាម្នាក់មកគាស់កកាយដែរ ។

## ខេត្តបន្ទាយមានជ័យ

នៅភូមិពក្វាក់ ឃុំគំរូ ស្រុកថ្មពួក មានរណ្ដៅសាកសពចំនួន៤ ស្ថិតនៅក្នុងបរិវេណបន្ទាយកងពលលេខ ៧ ដែលក្នុងនោះមានរណ្ដៅចំនួន ៣ ដែលមិនទាន់បានគាស់ ។

## ខេត្តសៀមរាប

ទីតាំងសម្លាប់ ព្រៃគ្រុយ មានរណ្ដៅចំនួន ៤ ។ រណ្ដៅទាំង៤នេះ ក្នុងរបាយការណ៍ដែនទីរណ្ដៅសាកសពមិនបានបញ្ជាក់ថា តើមានការគាស់កកាយហើយឬនៅទេ ។ ប៉ុន្តែបន្ទាប់ពីឆ្នាំរំដោះភ្លាមៗ គេសង្កេតឃើញមានពំនូកខោអាវយ៉ាងច្រើនអនេកបានគរនៅក្បែររណ្ដៅដែលកប់សាកសព ។ សាក្សីរាយការណ៍ថាមុនពេលសម្លាប់ ជនរងគ្រោះត្រូវសម្រាតខោអាវចេញអស់ ។

ស្រុកប្រាសាទបាគង

វត្តលលៃ

គឺជាទីតាំងសម្លាប់ផង និងជាមន្ទីរសន្តិសុខផង ។ នៅជុំវិញបរិវេណវត្ត គឺជាទីតាំងសម្លាប់ ។ កាលពីឆ្នាំ ១៩៩៧ គឺនៅពេលដែលក្រុមស្រាវជ្រាវទៅពិនិត្យ ទីតាំងនេះពុំទាន់មានការគាស់រណ្តៅឡើយ ហើយជាទីកន្លែងដែលមានព្រៃដុះច្រើន ។ រណ្តៅដែលខ្មែរក្រហមបានជីកគឺមានរាងជាប្រឡាយទឹក (ទទឹង១,៥០ម៉ែត្រ បណ្តោយ១២ម៉ែត្រ) ។ វត្តលលៃ ស្ថិតនៅក្នុងភូមិលលៃ ឃុំបាគង ស្រុកប្រាសាទបាគង ។

ស្រុកពួក

ទីតាំងសម្លាប់គោកតាម៉ែន

សាក្សីបានបញ្ជាក់យ៉ាងច្បាស់ថា សាកសពនៅក្នុងប្រឡាយគោកតាម៉ែន គឺគ្មានបានគាស់យកអដ្ឋិធាតុទៅដាក់នៅទីណាទេ ហើយបច្ចុប្បន្នដីខ្សាច់បានហូរកប់ឆ្អឹងអស់ ។ គោកតាម៉ែន ស្ថិតនៅក្នុងភូមិបឹងខ្នារ ឃុំខ្នាត ។ គោកតាម៉ែន គឺជាបន្ទាយរបស់ទាហាន ។ ឯប្រឡាយដែលយកធ្វើជាទីតាំងកប់សាកសព គឺជាលេណដ្ឋាន ។

សាក្សី៖

- ជួ វ៉ាន អាយុ៤៧ឆ្នាំ រស់នៅភូមិបឹងខ្នារ ឃុំខ្នាត ។
- មឿន ឈឿត អាយុ៤០ឆ្នាំ បច្ចុប្បន្នជំទប់លេខ៣ ឃុំខ្នាត ។
- ជីប សួន អាយុ៤០ឆ្នាំ សព្វថ្ងៃនៅភូមិបឹងខ្នារ ឃុំខ្នាត ។

កន្លែងសម្លាប់អណ្តូងទឹកតាម៉ន

ស្ថិតនៅក្នុងភូមិទឹកថ្លា ឃុំបឹងខ្នាត និងមានចម្ងាយពីសាលាស្រុក២គីឡូម៉ែត្រ ។ មានអណ្តូងទឹកមួយដែលខ្មែរក្រហមប្រើប្រាស់ជាកន្លែងកប់សាកសព មានទំហំមាត់លើ៣ម៉ែត្រ ជំរៅ៦ម៉ែត្រ ។ ខ្មែរក្រហមបានវាយអ្នកទោសទម្លាក់ចូលក្នុងអណ្តូងពេញ ហើយបច្ចុប្បន្នអណ្តូងនេះនៅពុំទាន់បានគាស់យកអដ្ឋិធាតុនៅឡើយ ។ ទីតាំងសម្លាប់អណ្តូងទឹក គឺមានដើមស្វាយ២ដើម ។ ជនរងគ្រោះដែលបានស្លាប់ក្នុងអណ្តូងនោះមានចំនួន ៧០ នាក់ ។

សាក្សី៖

- ហ៊ីង ប៊ីង បានដឹង ជាប្រធានការិយាល័យវប្បធម៌ស្រុកពួក ខេត្តសៀមរាប ។

# ខេត្តព្រៃវែង

ស្រុកស៊ីធរកណ្តាល

វត្តព្រៃស្វា

នៅជុំវិញបរិវេណវត្តព្រៃស្វា ភូមិព្រៃស្វា ឃុំជ្រៃឃ្មុំ មានរណ្តៅសាកសពច្រើនណាស់។ ខាងលិចព្រះវិហារមាន៦០រណ្តៅ ដែលក្នុង១រណ្តៅៗមានទំហំ ២ម៉ែត្របួនជ្រុង និងជម្រៅ១,៥០ម៉ែត្រ។ ចំណែកខាងជើង និងខាងត្បូងក៏មានរណ្តៅសាកសពច្រើនដែរ ប៉ុន្តែមិនបានរាប់ចំនួន។ ក្រៅពីបរិវេណខាងក្នុងវត្តនៅមានរណ្តៅធំជាងគេមួយទៀត។ សរុបជនរងគ្រោះដែលបានស្លាប់នៅទីនឹងទីតាំងសម្លាប់នេះ គឺមានចំនួនប្រហែល១៥០០នាក់។ ការសម្លាប់ខ្លាំងគឺកើតឡើងនៅឆ្នាំ១៩៧៨។ សាក្សីឈ្មោះ ប៊ូ ឡេា និង សយ អឿន ពុំបានបញ្ជាក់ថាមានការគាស់រណ្តៅសាកសពទាំងនេះហើយឬនៅទេ។

ទីតាំងសម្លាប់ក្បែរវិទ្យាល័យព្រៃកសណ្តែក

មានអណ្តូងទឹកចំនួន៥ដែលត្រូវបានប្រើប្រាស់ជាទីតាំងសម្លាប់កាលពីជំនាន់ខ្មែរក្រហម។ រហូតមកដល់បច្ចុប្បន្ននេះអណ្តូងទាំង៥ត្រូវបានលុបដីពីលើទាំងអស់។ ប៉ុន្តែគ្មានពត៌មានណាមួយបញ្ជាក់ថា អណ្តូងទាំងនេះបានគាស់ហើយឬនៅទេ។ អណ្តូងទាំង៥នោះគឺ៖

ក) អណ្តូងទឹក នៅផ្ទះតាអុន

ខ) អណ្តូងទឹក ផ្ទះតាហ៊ើយ-ទា

គ) អណ្តូងទឹក ផ្ទះ តាង៉ាន់

ឃ) អណ្តូងទឹក ផ្ទះតាហុង

ង) អណ្តូងខាងលិចវិទ្យាល័យព្រៃកសណ្តែក។

សាក្សី៖

-នាយកវិទ្យាល័យព្រៃកសណ្តែកឈ្មោះ ហាក់ ស្រ៊ុន។

-មឿង ហុង សេង ជាអតីតជនរងគ្រោះ។

វត្តព្រៃដើមថ្នឹងខាងជើង

ស្ថិតនៅភូមិដើមថ្នឹង ឃុំព្រៃដើមថ្នឹង ស្រុកស៊ីធរកណ្តាល។ ជនរងគ្រោះទាំងគ្រួសារៗ ត្រូវបានសម្លាប់នៅទីងអណ្តូងទឹក១ និងរណ្តៅចំនួន៥ផ្សេងទៀត។ រណ្តៅទាំង៤នោះគឺ ១ ស្ថិតនៅខាងក្រៅវត្ត និង ៣ទៀតស្ថិតនៅក្នុងបរិវេណវត្ត។ តាមរបាយការណ៍ពីសាក្សីបានឲ្យដឹងថា រណ្តៅទាំងអស់មានផ្ទុកសាកសពពេញៗដល់មាត់រណ្តៅ ហើយពុំមាននរណាគាស់រកមាសដែរ។

សាក្សីៈ

- យ៉ាន យាន រស់នៅភូមិដើមថ្នឹង ឃុំព្រៃដើមថ្នឹង ។

-ព្រះសង្ឃ គ្រួច គាវ គង់នៅវត្តព្រៃដើមថ្នឹង ។

វត្តព្រៃឈៀង

មានរណ្តៅសាកសពចំនួន៤០ និងអណ្តូងទឹកចំនួន ១ ដែលស្ថិតនៅនឹងទីតាំងវត្តព្រៃឈៀង ។ វត្តព្រៃឈៀង ស្ថិតនៅក្នុងភូមិព្រៃឈៀង ឃុំព្រៃឈៀង ។ មានជនរងគ្រោះប្រមាណពី១១២០ ទៅ ២៥០០ នាក់ បានស្លាប់នៅនឹងទីតាំងនេះ ។ ទំហំរណ្តៅគឺ ៤ម៉ែត្រការេ ជម្រៅ២ម៉ែត្រ ។ ពុំមានការបញ្ជាក់ណាមួយជុំវិញការគាស់រណ្តៅសាកសពនេះទេ ។

ស្រុកមេសាង

ទួលមេសាង ឬផ្សារមេសាង

នៅប៉ែកខាងក្រោយផ្ទះរបស់ឈ្មោះ វុទ្ធី ស្ថិតនៅក្នុងភូមិទួលមេសាង ឃុំព្រៃរំដេង មានទីតាំងសម្លាប់មួយដែលមានតែមួយរណ្តៅគត់ (ទំហំរណ្តៅបណ្តោយ៨ម៉ែត្រ ទទឹង២ម៉ែត្រ និងជម្រៅ១,៥០ម៉ែត្រ) ហើយមានផ្ទុកសាកសពពី១៥០នាក់ទៅ២៥០នាក់ ។ សាកសពគឺជា អតីតកងពល័ត កម្មកររោងចក្រកាត់ដេរ និងកម្មករចម្ការកៅស៊ូ ។ រហូតមកដល់បច្ចុប្បន្ននេះ សាក្សីរាយការណ៍ថា មិនទាន់មាននរណាមកជីករណ្តៅនេះទេ ។

សាក្សីៈ

-ប៊ុន ឃឿន រស់នៅភូមិទួលមេសាង ឃុំព្រៃរំដេង ។

-មួន ស៊ន់ រស់នៅភូមិទួលមេសាង ឃុំព្រៃរំដេង ។

ទួលដើងចាប

មានទីតាំងស្ថិតនៅក្នុងឃុំព្រៃទទឹង ស្រុកមេសាង ។ មានទីតាំងសម្លាប់ចំនួនបីកន្លែង ដែលស្ថិតនៅក្នុងទីតាំងសម្លាប់ទួលដើងចាបៈ

ក) អណ្តូងទឹកចំនួន ២ :

ស្ថិតនៅខាងត្បូងផ្ទះរបស់ឈ្មោះ យ៉ែម ស៊ីម ។ ទីតាំងនេះមានសាកសពប្រហែលពី១៣៨នាក់ទៅ ១៥០នាក់ និងនៅមានស្លាកស្នាមនៅឡើយ ។

ខ) ដំបូកដើមរការៈ

មានអណ្តូងមួយ ដែលបានផ្ទុកសាកសពប្រមាណពី ៨០នាក់ទៅ១២០នាក់ ។

ក) ត្រពាំងចំបក់

ទីតាំងនេះមានដើមក្រសាំងមួយដើមសម្រាប់សម្គាល់ ។ មានរណ្តៅចំនួន ៣ ដែលក្នុងនោះមានរណ្តៅតូចតែ ១ ទេគឺទំហំ២ម៉ែត្រការេ និងជម្រៅ២ម៉ែត្រ ។

ស្រុកកំចាយមារ

មានរណ្តៅសាកសពចំនួន ២ ស្ថិតនៅក្បែរគុកគាសំ ក្នុងភូមិគាសំ ឃុំក្រញូង ។ រណ្តៅសាកសពទាំងពីរនេះមិនទាន់មាននរណាគាស់ឡើយ ប៉ុន្តែជាទីកន្លែងដែលលិចទឹកនៅខែទឹកគម្រឹង ហើយនៅជាវាលស្រែនៅរដូវទឹកសម្រក ។

ស្រុកពារាំង

មានរណ្តៅសាកសពចំនួន ៨៣ នៅលើទួលស្វាំង នាឃុំព្រៃស្រឡិត ហើយដែលរណ្តៅទាំងនោះពុំទាន់បានគាស់ឡើយ ។

សាក្សី៖

-ថោង ជ័យ មេឃុំព្រៃស្រឡិត ។

-ជុន សិត រស់នៅភូមិគ្រាំង ឃុំព្រៃស្រឡិត ។

## ខេត្តតាកែវ

ស្រុកកោះអណ្តែត

ទីតាំងព្រៃសុខុន

ជាទីតាំងសម្ងាប់មួយដែលមានសាកសពពី១២០០០នាក់ទៅ១៥០០០នាក់ ។ ទំហំទីតាំង គឺមានប្រវែង ៤ ហិកតា ។ ជនរងគ្រោះមានលាយចម្រុះទាំងខ្មែរ និងកម្ពុជាក្រោម ។ ពុំមានការបញ្ជាក់ពីការគាស់រកមាសឡើយ ។ រណ្តៅធំៗចំនួន៤ បានត្រូវបង្ហាញថាមានទំហំ១០ម៉ែត្រការ៉េ និងជម្រៅ២ម៉ែត្រ ។

សាក្សី៖

-ស៊ុំ ជុំ អាយុ៣៨ឆ្នាំ រស់នៅភូមិស៊ីស្លា ឃុំផ្លាប្រជុំ ស្រុកកោះអណ្តែត ។

-អ៊ុន ហ៊ិន រស់នៅភូមិស៊ីស្លា ឃុំផ្លាប្រជុំ ស្រុកកោះអណ្តែត ។

-វង់ ហឿង រស់នៅភូមិស៊ីស្លា ឃុំផ្លាប្រជុំ ស្រុកកោះអណ្តែត ។

ស្រុកសំរោង

វត្តស្រះក្រាំងបន្ទាយ (ភូមិពេជ្រឥន្ទ្រា ឃុំបឹងត្រាញ់)

មានរណ្តៅប្រហែល១៣០រណ្តៅ ស្ថិតនៅជុំវិញបរិវេណវត្តស្រះក្រាំងបន្ទាយដែលជាកន្លែងសន្តិសុខរបស់ខ្មែរក្រហម ។ យ៉ាងហោចណាស់មានសាកសពចំនួនពីរនាក់ដែលត្រូវបានកប់ក្នុងរណ្តៅមួយ ។ ពុំមានពត៌មានណាមួយបញ្ជាក់ពីការជីកគាស់រណ្តៅទាំងនោះឡើយ ។

ស្រុកត្រាំកក់

គុកព្រៃក្តួច (ភូមិព្រៃក្តួច ឃុំក្រញូង)

ព្រៃក្តួច គឺជាមន្ទីរសន្តិសុខមួយយ៉ាងធំរបស់ខ្មែរក្រហម ដែលបានសម្រាំងយកតែជនរងគ្រោះណាដែលមានប្រវត្តិរូបមិនល្អ ដូចក្នុងករណីអ្នកដែលមានជាប់ពាក់ពន្ធ័រឿងនិន្នាការនយោបាយ និងអ្នកដែលមានបងប្អូននៅភ្នំពេញជាដើម ។ ការសម្លាប់បានកើតឡើងជាហូរហែរនៅនឹងទីតាំងនោះ ។ មានអ្នកទោសមួយចំនួនត្រូវបានបញ្ជូនមកពីមន្ទីរសន្តិសុខភ្នំសន្លុង និងក្រាំងតាចាន់មកកាន់មន្ទីរសន្តិសុខដ៏ធំនេះ ។ គ្មាននរណាម្នាក់បានដឹងថាមានការសម្លាប់មនុស្សនៅទីតាំងគុកព្រៃក្តួចឡើយ ប៉ុន្តែនៅក្រោយឆ្នាំ១៩៧៩ សាកសពយ៉ាងច្រើនត្រូវបានប្រទះឃើញនៅក្នុងរណ្តៅយ៉ាងច្រើនអនេកក្បែរជើងភ្នំ ។ អ្នកស្រុកភូមិបានសន្និដ្ឋានទៅលើសាកសពទាំងនោះថា ទំនងជាត្រូវបានដុតទាំងរស់ ។ រហូតមកដល់សព្វថ្ងៃនេះ រណ្តៅសាកសពទាំងប៉ុន្មានដែលទ្រុឌទ្រោមដោយការរង្លេះរលួយបន្ទាប់ពីសាកសពហើមពោរពាសមក ត្រូវបានចាក់លប់ដីភ្លិតវិញដោយសារទឹកភ្លៀងច្រោះ ហើយរណ្តៅទាំងនោះ ពុំទាន់មាននរណាម្នាក់គាស់ឡើយ ។ ការស្រាវជ្រាវត្រូវធ្វើឡើងនៅរដូវរាំងស្ងួត ។ ចម្ងាយពីទីរួមខេត្តតាកែវ៦០គីឡូម៉ែត្រ ។

សាក្សី៖

- មុត ហុន ប្រធានភូមិព្រៃក្តួច ឃុំក្រញូង ។

# ខេត្តពោធិសាត់

ស្រុកបាកាន

ទីតាំងសម្លាប់ ព្រៃភាគ

ទីតាំងនេះមានទំហំដី ២,៥០គីឡូម៉ែត្រការ៉េ ។ មានរណ្តៅច្រើនណាស់ដែលមិនអាចរាប់បាន ។ មានសាកសពពេញៗនៅគ្រប់រណ្តៅទាំងអស់ ។ តាមការមើលឃើញជាក់ស្តែងរបស់ក្រុមស្រាវជ្រាវទៅលើដីនៃ

បរិវេណទីតាំងសម្លាប់ គឺឃើញមានឆ្អឹងខ្លះៗ និងក្រណាត់ខោអាវខ្លះនៅពាសពេញដី ។ ទោះជាយ៉ាងនេះក៏ដោយ ក៏ពុំមានការបញ្ជាក់ណាមួយស្តីពីការគាស់រណ្តៅសាកសពនេះដែរ ។

ស្រុកកណ្តៀង

ទួលពោធិ៍ជ្រៃ

ចម្ងាយ១៥គីឡូម៉ែត្រពីសាលាស្រុក ។ ទួលពោធិ៍ជ្រៃ គឺជាអតីតបន្ទាយទាហានរបស់លន់ ណុល ។ មានរណ្តៅច្រើននៅក្រោមដើមពោធិ៍ជ្រៃ ក្នុងភូមិព្រីងខ្ពស់ ឃុំស្រែស្តុក ។

ស្រុកក្រគរ

ទីតាំងសម្លាប់ទួលលៀប

ស្ថិតនៅក្នុងភូមិទួលលៀប ឃុំបឹងកន្ទួត ។ មានរណ្តៅពី៤០០-៥០០រណ្តៅ ដែលក្នុង១រណ្តៅអាចកប់សាកសពបាន ៧ នាក់ ។ ព្រៃទួលលៀប មានទំហំ២០០ម៉ែត្រទទឹង និងបណ្តោយ៣០០ម៉ែត្រ ។ ពុំមានការបញ្ជាក់ណាមួយស្តីពីការគាស់រណ្តៅសាកសពឡើយ ។

សាក្សី៖

-ញ៉ែម ឌុល ជាអតីតអ្នកកប់ខ្មោចនៅទួលលៀប ។ សព្វថ្ងៃរស់នៅភូមិជ្រលុង ឃុំអន្ទង់ត្នោត ។

ទីតាំងសម្លាប់តាវិត

មានរណ្តៅពី៥០-៦០រណ្តៅ ។ ជនរងគ្រោះគឺជាប្រជាជនជម្លៀស ប្រជាជនចាស់ ចិន យួន និងចាម ។ សរុបជន រងគ្រោះទាំងអស់ពី១០០-១៥០នាក់ ។ ពុំមានការនិយាយពីការគាស់រណ្តៅសាកសពឡើយ ។

សាក្សី៖

-ញ៉ែម ឌុល ជាអតីតអ្នកកប់ខ្មោចនៅទួលលៀប ។ សព្វថ្ងៃរស់នៅភូមិជ្រលុង ឃុំអន្ទង់ត្នោត ។